| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | វិទ្យាសាស្រ្ត |
| **ប្រធានបទ** | អាហាររូបត្ថម្ភ:<br>សកម្មភាពសង្កេតបន្លែ និងផ្លែឈើ |
| **ចំណងជើងមេរៀន** | ល្បែងទាយផ្លែឈើ និង បន្លែ |
| **កម្រិត** | មធ្យម ៣០ នាទី |
| **គោលបំណង** | ដើម្បីឱ្យកុមារស្គាល់ពីឈ្មោះបន្លែ ផ្លែឈើផ្សេងៗ និងក្រុមអាហារដែលជួយដល់សុខភាព។ |
| **បំណិនសម្បទា** | -ប្រាប់បានពីឈ្មោះបន្លែ ផ្លែឈើជួយទ្រទ្រង់ដល់សុខភាពរាងកាយ។ |
| **ចរិយាសម្បទា** | -បម្រុងប្រយ័ត្នអាហារខូចៗចូលចិត្តញ៉ាំផ្លែឈើ បន្លែឆ្អិន និងអាហារល្អៗ។ |
| **គ្រូបង្រៀន** | ទិញដោយជ្រើសរើសបន្លែផ្លែឈើណាដែលអាចបរិភោគនៅបាន ដោយបិទភ្នែកដោយកន្សែង ឬក្រមា ។ |
| **កុមារ** | អង្គុយឬឈរដោយភាពស្ងាត់ស្ងៀម ស្តាប់គ្រូ។ |
| **រៀបចំ** | កាត់ផ្លែឈើ និងបន្លែ ជាចំណែក ឬដុំតូចៗ (និងទុកផ្លែឈើនិងបន្លែទាំងមូលសម្រាប់ឱ្យក្មេងៗមើលពេលទាយខុស)។<br>ទុកកន្លែងក្មេងៗមើលមិនឃើញផង។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
| --- | --- | --- |
| 1. បង្ហាញក្មេងៗពីផ្លែឈើ និងបន្លែទាំងអស់និង សួរពួកគេថាតើពួកគេហៅ បែបណា?<br>2. សួរពួកគេថាហេតុអ្វី បានជាផ្លែឈើនិងបន្លែមាន ប្រយោជន៍សម្រាប់ ប្រព័ន្ធភាពសាំុ ។<br>3. ពន្យល់ពីរបៀបដែល ផ្លែឈើ និងបន្លែជួយ ដល់ការប្រយុទ្ធប្រឆាំងជាមួ យមេរោគរបស់ ប្រព័ន្ធភាពសាំុ។<br>4. ពិភាក្សាពីផ្លែឈើ និង បន្លែដែលពួកគេចូល ចិត្ត។<br>5. ពន្យល់ពីការលេង ល្បែងមួួយនេះឱ្យបានច្បា ស់ ។<br>6. សួរពួកគេតើមាននរណាដែ លចង់លេងមុន គេ។<br>7. បិទភ្នែកពួកគេដែលលេងដំ បូង និងដាក់ផ្លែឈើ | 1. ប្រាប់ពីផ្លែឈើនិងបន្លែមាន ផ្ទុកវីតាមីននិងសារធាតុប្រ ឆាំងនឹងអុកស៊ីតកម្មដែល អាចជួយដល់ប្រព័ន្ធភាព សាំុប្រឆាំង នឹងមេរោគ។<br>2. នៅក្នុងចាននីមួយៗ មានផ្លែឈើ និងបន្លែ ផ្សេងៗគ្នាបិទភ្នែកពួកគេ នៅពេលដែលលេងល្បែង ដោយប្រើកន្សែង ឬក្រមា។ បន្ទាប់មកចែកចានបន្លែ និងផ្លែឈើ ឱ្យក្មេងៗ សាក់ភ្លក់ ។<br>3. ពួកគេត្រូវព្យាយាម ទាយថាអ្វីដែលពួកគេបាន ភ្លក់នោះគឺជា ផ្លែឈើ ឬ បន្លែ។ | 1. យកចិត្តទុកដាក់ស្តាប់គ្រូ និងឆ្លើយសំណួរ ។<br>2. ប្រសិនបើអ្នកចង់លេងល្បែ ងមុនអ្នកត្រូវលើកដៃនៅពេ លដែលគ្រូសួរអ្នក ។<br>3. ភ្លក់អ្វីដែលអ្នកគ្រូបានឱ្យអ្ន ក។ ទំពារយឺតៗ ដោយគិតពីរស់ជាតិ របស់វា ថាផ្អែម ឬអត់។ តើអ្នកធ្លាប់បានញ៉ាំវាពីមុន ដែរឬទេ? ទាយថាវាគឺជាផ្លែឈើ ឬជាបន្លែ? |

| | | |
|---|---|---|
| និងបន្លែនៅពីមុខពួកគេ ដើម្បីភ្លក់។<br>8. ប្រាប់ពួកគេថាកុំធ្វើទឹកមុខ ប្រែប្រួលនៅពេលដែល ញុាំប៉ះបន្លែឬផ្លែឈើណា ដែលអ្នកមិន ចូលចិត្តញុាំ (ធ្វើទឹកមុខ ធម្មតា)។ពួកគេគួរតែ ទំពារឱ្យលឿន។<br>9. ឱ្យពួកគេលេបវាដោយយឺត ៗដើម្បីដឹងពីរស់ ជាតិរបស់វា ហើយសួរ ពួកគេថាវាផ្អែមមែនទេ? តើអ្នកធ្លាប់ហូបវាពីមុនមក ទេ? តើអ្នកដឹងទេថាវាគឺជា អ្វី?<br>10. បន្តលេងល្បែងមួយនេះរហូតដល់អស់ក្មេងៗ។<br>11. បង្ហាញក្មេងៗពីផ្លែឈើ និងបន្លែទាំងអស់ដែលពួក គេបានព្យាយាម ទាយនោះ។<br>12. សួរពួកគេថាតើកូនៗស្គាល់ ឈ្មោះផ្លែឈើ | | |

| | | |
|---|---|---|
| និងបន្លែទាំងអស់នេះ ដែរឬទេ?<br>13. បន្ទាប់មកសរសេរឈ្មោះបន្លែ និងផ្លែឈើនៅលើក្ដារខៀន។<br>14. ចូរសួរក្មេងៗដែលមិនទាន់បានញ៉ាំផ្លែឈើ និងបន្លែ ថាតើកូនៗចូលចិត្តញ៉ាំវាទេ?<br>15. ប្រសិនបើផ្លែឈើ និងបន្លែយើងនៅសល់ អ្នកអាចចែកជាមួយក្មេងៗបានប៉ុណ្ណឹងគឺជាការស្រេច។ | | |